**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៤៨ប្រ
ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៩
**សាលដីកា**
លេខ:១៤៤ប្រ
ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក .......... ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-លោកស្រី ..............

**តំណាងមហាអយ្យការ**
-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ២៨ថ្ងៃទី១៩-០១-៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ០១ ចុះថ្ងៃទី០៦-៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះធគធ ភេទប្រុសអាយុ ៤៣ឆ្នាំ ជាតិខ្មែររបរកស៊ី លក់ដែក មានទីលំនៅសព្វថ្ងៃភូមិវត្ត ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ។ ឪពុកឈ្មោះតេង ហ៊ត (រ) ម្តាយឈ្មោះយ៉ុង អេង (រ) ប្រពន្ធឈ្មោះ ហេង ស៊ីណេត មានកូន០៤ នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះភស ភេទប្រុស អាយុ៦៧ឆ្នាំ ជាតិខ្មែរ របរកស៊ីបើក មានទីលំនៅភូមិ-ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ។ ឪពុកឈ្មោះស៊ុយ (ស)ម្តាយឈ្មោះនាង ហុង (ស) ប្រពន្ធឈ្មោះអ៊ិក ឡូត មានកូន០៣ នាក់ ។ (ឪពុករបស់ ចុងចម្លើយឈ្មោះភី យុនឌី ) ។

មានមេធាវីឈ្មោះ............. ។

**កម្មវត្ថុបណ្តឹង** ប្តឹងកិច្ចការប្រញាប់ សុំឱ្យឪពុករបស់ចុងចម្លើយឈ្មោះភស ចុះចេញពីផ្ទះរបស់ខ្លួន ។

បានឃើញបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ របស់លោកតេង គន្ធី បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ២៨ ចុះថ្ងៃទី១៩ ខែមករាឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៨ប្រ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ របសតុលាការកំពូល ។

តាមពាក្យបណ្តឹងសុំកិច្ចការប្រញាប់របស់លោកតេង គន្ធី ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៨ យោងនឹងពាក្យបណ្តឹងអង្គសេចក្តីបានបញ្ជាក់ថា ឈ្មោះភស ដែលជាឪពុកលោកភី យុនឌី ពុំមានការ ពាក់ព័ន្ធក្នុងការទិញលក់នេះទេ ដោយកាលពីថ្ងៃទី២ ខែមេសា ឆ្នាំ១៩៩៨ ខ្លួននឹងប្រពន្ធបានទិញផ្ទះពីឈ្មោះភី យុនឌី និងប្រពន្ធឈ្មោះហ៊ុន ហាក់ពាន់ ក្នុងតម្លៃ ២១.០០០ដុល្លាអាមេរិក លើទំហំផ្ទះ ដែលមានជាន់ក្រោមផ្ទាល់ដីជាន់ទី១ ជាន់ទី២ ដោយបានធ្វើកិច្ចសន្យាលិខិតផ្ទេរ

កម្មសិទ្ធិផ្ទះ ដែលព្រមព្រៀង គ្នាប្រគល់ឱ្យខ្លួននៅថ្ងៃទី៦ ខែ៥ ឆ្នាំ១៩៩៨ តែភាគីអ្នកលក់ផ្ទះឈ្មោះភី យុនឌី និង ប្រពន្ធបានសុំពន្យាពេល ឱ្យឪពុកស្នាក់នៅលើផ្ទះនោះមួយខែទៀត រិះរកកន្លែងថ្មីបាន ដូចនេះខ្លួនសុំឱ្យឪពុករបស់ ឈ្មោះភី យុនឌី ឈ្មោះភស ចុះចេញពីផ្ទះរបស់ខ្លួន ពីព្រោះហួសពេលកំណត់សន្យាហើយ ។

បានឃើញសាលដីសម្រេចកិច្ចការប្រញាប់លេខ១១៣,ស ៩៨ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការខេត្ត ក្រចេះ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងកិច្ចការប្រញ៉ាប់ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៨ របស់ដើមចោទុកជា ត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-បង្គាប់ឲ្យឈ្មោះភស ជាតតិយជន ចុះចេញពីផ្ទះលោកតេង គន្ធី និងលោកស្រីហេង ស៊ីណេត ព្រមទាំងពីស ម្ភារៈតវ៉ាន់របស់ខ្លួនចេញឱ្យអស់ពីផ្ទះរបស់ដើមចោទ ជាបណ្តោះអាសន្ន ទំរាំដល់ ពេលណាតុលាការសម្រេចដល់អង្គ សេចក្តីនៃរឿង ។

៣- បង្គាប់ឱ្យមន្ត្រីយុត្តិធម៌ អនុវត្តឱ្យបានសម្រេចតាមដីកានេះ ។

៤- ប្រាក់ប្រដាប់ក្តី ២.០០០រៀល ត្រូវរឹបអូស ។

សេចក្តីសម្រេនេះមានអានុភាពអនុវត្តភ្លាមៗ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់លោកភស ដែលប្តឹងជំទាស់នឹងដីកាសម្រេចកិច្ចការប្រញាប់លេខ១១៣.ស៩៨ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការខេត្ត លើដីកាសម្រេចកិច្ចការប្រញាប់ ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមាន ខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់ឈ្មោះភស ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិ ច្បាប់ ។

២-បដិសេធកិច្ចការប្រញាប់លេខ១១៣,ស ៩៨ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការខេត្តក្រចេះចោលជា អសារបង់ ។

៣- បង្គាប់ឱ្យឈ្មោះភស រស់នៅលើផ្ទះទំនាស់ និងទ្រព្យសម្បត្តិត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ រស់នៅបន្តទៀតរង់ ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៥- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី២៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៤០០០រៀល អាជ្ញាធរតុលាការ៥០០០រៀល សរុប១៣០០០រៀល ។ កាលបើហួសបណ្តឹងសាទុក្ខបង្គាប់ឱ្យដើមចោទឈ្មោះតេង គន្ធី ប្រគល់ប្រាក់នេះឱ្យទៅចុង ចម្លើយវិញ ។

៥- សាលដីកានេះ មានអនុភាពអនុវត្តន៍ភ្លាមៗ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីចុងចម្លើយ និងចុងចម្លើយឈ្មោះភី យុនឌី និង កំបាំងមុខឈ្មោះភស និងដើមចោទឈ្មោះតេង ឌី បើកផ្លូវប្តឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ របស់លាកតេង គន្ធី បានប្តឹងមិនសុខចិត្ត នឹងសាលដីកាលេខ២៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៩ របស់ឈ្មោះតេង គន្ធី

បានឃើញសារណាតបចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៩ របស់ឈ្មោះភស

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

សាលដីកានេះមានការខុសឆ្គងទាំងទម្រង់ទាំងគតិច្បាប់គប្បីបដិសេធចោល ហើយបញ្ជូនសំណុំរឿងនេះទៅតុលាការខេត្តក្រចេះដើម្បីចាត់ការតាមនីតិវិធី ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះតេង គន្ធី ជាដើមចោទ និងជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថាឈ្មោះភស មិនព្រមចុះចេញពីផ្ទះនេះទេ គឺគាត់មិនគោរពកិច្ចសន្យាដែលកូនគាត់បានចុះកិច្ចសន្យាជាមួយខ្ញុំ មិនតែប៉ុណ្ណោះគាត់ធ្វើសកម្មភាពគ្រប់បែបយ៉ាង រំខានដល់ការរកស៊ីរបស់ខ្ញុំ ដូចជាដាក់ថ្នាំក្នុងអាងទឹកបំពុលភ្ញៀវ ពេលគាត់ឡើងជណ្តើរទៅផ្ទះគាត់ គាត់បើកទ្វារចំហរ ក្នុងគោលបំណងឱ្យចោរចូលលួចម៉ូតូរបស់ភ្ញៀវ គាត់លក់សាំងកន្លែងភ្ញៀវចេញ-ចូល វាអាចឆេះបាននៅពេលដែល ភ្ញៀវបោះកន្ទុយចាំរីទៅ ។ ពេលខ្ញុំចាក់សោរគាត់ឡើងទៅលើមិនរួច គាត់ពុះទ្វារផ្ទះចោល ហើយទំនាស់នេះ កើតឡើងជាញឹកញាប់ ។ ខ្ញុំសំណូមពរឱ្យភស គោរពកិច្ចសន្យាដែលកូនគាត់បានធ្វើជាមួយខ្ញុំ ។

បានស្តាប់ចម្លើយរបស់ឈ្មោះភស ជាចុងចម្លើយ និងជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា៖ ការលក់ដូរផ្ទះរបស់កូនខ្ញុំមិនដឹងទេ គឺគេលក់តែផ្ទះរបស់គេ គឺជាន់$E_0$+$E_1$ ចំណែកខ្ញុំនៅជាន់ទី $E_2$ ហើយពេលខ្ញុំទៅសួរពួកសុរិយោដី គេក៏ប្រាប់ថា ផ្ទះនោះមានប្លង់ដាច់ពីគ្នា ហើយផ្ទះ នេះខ្ញុំនៅតាំងពីឆ្នាំ១៩៨៦ មកម្ល៉េះ ស្រាប់តែនៅថ្ងៃទី០៨-១២-៩៨ មានកងកំលាំងប្រដាប់អាវុធមកប្រើ អំពើហឹង្សា ដេញខ្ញុំឱ្យចុះចេញពីផ្ទះរហូតមកដល់សព្វថ្ងៃ ។ ខ្ញុំមិនបានមានគំនិតដាក់ថ្នាំ និងលក់សាំងកន្លែងភ្ញៀវចេញ-ចូលទេ ។

បានស្តាប់សចក្តីសន្និដ្ឋានរបស់មេធាវីឈ្មោះ............ ការពារឱ្យលោកភស នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា៖ តាមកិច្ចការប្រញាប់លេខ១១ពស.៩៨ ចុះថ្ងៃទី០៨-១២-៩៨ របស់តុលាការខេត្តក្រចេះ បានសម្រេចបណ្តេញឱ្យកូនក្តីខ្ញុំចុះចេញពីផ្ទះទំនាស់ ដែលជាផ្ទះដោយឡែក ហើយកូនក្តី ខ្ញុំរស់នៅមុនកិច្ចសន្យារបស់កូនគាត់ជាមួយ តេង គន្ធី ហើយមានជណ្តើរឡើងទៅលើនៅចំហៀងផ្ទះ មិនមែននៅក្នុងផ្ទះទេ ។ ការធ្វើបែបនេះ ផ្ទុយពីសារាចរណ៍ណែនាំលេខ០៤ ស./៨៩ ចុះថ្ងៃទី ០៨-០៩-៨៩ របស់ក្រសួងយុត្តិធម៌ស្តីពីនីតិវិធីរដ្ឋប្បវេណី ដែលមានគោលដៅការពារការអន្តរាយផ្សេងៗ តែនេះធ្វើឱ្យកូនក្តីខ្ញុំបាត់បង់លំនៅដ្ឋាន ។ ដូច្នេះសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សចក្តីសន្និដ្ឋាន របស់ណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូក្តី និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ របស់លោកតេង គន្ធី ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ក្នុងការសម្រេចសេចក្តី សាលាឧទ្ធរណ៍មានការខុសឆ្គងផ្នែកទម្រង់ច្បាប់ជាច្រើន អន្លើ ដែលនាំឱ្យមោឃភាពសាលដីកានេះបានដូចជាៈ

-សាលាឧទ្ធរណ៍ បានចេញដីកាកោះឲចូលរួមសវនាការ មានរយៈពេល៥ថ្ងៃប៉ុណ្ណោះ ។

-សាលាឧទ្ធរណ៍ បានចេញសំរង់សាលដីការដ្ឋប្បវេណីនៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ ប៉ុន្តែការជំនុំជំរះទើតែធ្វើនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ ដូច្នេះកាចេញសំរង់សាលដីកានេះ ធ្វើមុនថ្ងៃជំនុំជំរះទៅទៀត ។

-សាលដីការដ្ឋប្បវេណី នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ១៩៩៩ ប៉ុន្តែការជំនុំជំរះទើបតែធ្វើនៅថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ ដូច្នេះការចេញសំរង់សាលដីកានេះ ធ្វើមុនថ្ងៃ
ជំនុំជំរះទៅទៀត ។

-សាលាឧទ្ធរណ៍ បានសម្រេចថា សាលដីកានេះមានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹង សាទុក្ខក៏ដោយ ការសម្រេចបែបនេះផ្ទុយនឹងមាត្រា១៣ នៃច្បាប់ស្តីពីការទាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២១៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ពីព្រោះថាបណ្តឹងសាទុក្ខនិងរយៈពេលប្តឹងសាទុក្ខ មានអានុភាពផ្អាក់ជាបណ្តោះអាសន្ននូវការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សម្រេចឱ្យលោកភស រស់នៅលើផ្ទះទំនាស់នេះបន្ត និងប្រគល់ទ្រព្យសម្បត្តិឱ្យម្ចាស់ដើម្បីវិញ រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី នោះជាការត្រឹមត្រូវ តាមគោលការណ៍នៃកិច្ចការប្រញាប់ហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងផ្នែកទម្រង់ច្បាប់ខ្លះ ប៉ុន្តែផ្នែកគតិច្បាប់មាន លក្ខណៈត្រឹមត្រូវហើយ ។

## ហេតុដូច្នេះ

## ១និច្ឆ័យសេចក្តចំពោះមុខគូភ្ត

១- ទទួលបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ របស់លោកតេង គន្ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្វិល ។

៣- លើកពាក្យបណ្តឹងកិច្ចការប្រញាប់ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៨ របស់លាកតេង គន្ធី ចោលជាអសារបង់ ។

៤- សម្រេចឱ្យលោកភស រស់នៅលើផ្ទះទំនាស់នេះជាបណ្តោះអាសន្នបន្តទៀត រហូតដល់តុលាការសម្រេចដល់អង្គសេចក្តីជាស្ថាពរ និងតម្រូវឱ្យប្រគល់ទ្រព្យសម្បត្តិដែលរើចេញ ឱ្យម្ចាស់ដើមវិញ ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកភស បង់ជំនួសគឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ -

-ចំណាយក្នុងការប្រគល់ដីកាកោះ ចំនួន ១៥០០០រៀល សរុប ១៩០០០រៀល ហើយតម្រូវឱ្យម្ចាស់បណ្តឹងសាទុក្ខ សងប្រាក់នេះទៅលោកភស វិញ ។

៦- បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ៤៨ប្រ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការកំពូល ទៅតុលាការខេត្តក្រចេះ ដើម្បីបញ្ចូលក្នុងសំណុំរឿងនៃអង្គសេចក្តី ។

៧- សាលដីកានេះ ប្រកាសនោះសវនាការ ជាសាធារណៈ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩ ។